# Préfaces

# **Carole Delga,**
## présidente de la région Occitanie

តំបន់អុកស៊ីតានី (Occitanie) និងខេត្តបាត់ដំបងនៅឆ្ងាយពីគ្នាដល់ទៅ១២ ០០០គីឡូម៉ែត្រ។ ប៉ុន្តែតំបន់ទាំងពីរនេះមានសក្តានុពលខ្លាំងដូចគ្នាខាងវិស័យកសិកម្ម ភាពសម្បូរបែប និងចម្រុះនៃបេតិកភណ្ឌវប្បធម៌ និងខាងវិស័យទេសចរណ៍ ដែលយើងគ្រប់គ្នាដឹងច្បាស់។ កត្តាទាំងនេះបានបណ្តាលឲ្យតំបន់ទាំងពីរនេះមានទំនាក់ទំនងនឹងគ្នាតាមរយៈការសិក្សា និងគម្រោងស្រាវជ្រាវជាមួយគ្នា មិនត្រឹមតែប៉ុណ្ណោះថែមទាំងបានរីតចំណងមិត្តភាពកាន់តែរឹងមាំចាប់តាំងពីឆ្នាំ២០១៥តរៀងមក។

នៅក្នុងកិច្ចសហប្រតិបត្តការនេះ តំបន់អុកស៊ីតានីបានធ្វើការសម្រេចចិត្តប្រកបដោយភាពជឿជាក់យ៉ាងមុតមាំ រួមសហការដឹកនាំសកម្មភាពការងារជាមួយសមាគម អង្គការក្រៅរដ្ឋាភិបាល គ្រឹះស្ថានឧត្តមសិក្សានានាក្នុងតំបន់អុកស៊ីតានី ដែលជាដៃគូសហការជាមួយភាគីកម្ពុជានៅលើវិស័យជាច្រើន ជាអាទិ៍វិស័យកសិកម្ម អប់រំ បេតិកភណ្ឌវប្បធម៌ សុខាភិបាល និងយុត្តិធម៌ជាដើម។

កន្លងមក យើងតែងតែជួបការលំបាកក្នុងការកំណត់តម្រូវការអាទិភាពចាំបាច់សម្រាប់ខេត្តបាត់ដំបង។ យើងតែងតែប្រាថ្នាឲ្យមានទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងក្រុមការងារបច្ចេកទេស អ្នកជំនាញក្នុងតំបន់និងតាមមូលដ្ឋាន និងអាជ្ញាធរជាតិ ដើម្បីរកដំណោះស្រាយ។

មិនយូរប៉ុន្មាន យើងក៏អាចសម្រេចយកការងារអភិរក្ស និងការលើកតម្កើងបេតិកភណ្ឌវប្បធម៌នៅខេត្តបាត់ដំបងគឺជាស្នូលនៃកិច្ចសហការរបស់យើង ដែលនៅក្នុងនោះរួមមានការពង្រឹងផ្នែកបណ្តុះបណ្តាលជំនាញ ជាពិសេសនៅក្នុងក្របខណ្ឌសាកលវិទ្យាល័យ។ ឆ្លើយតបនឹងតម្រូវការចាំបាច់នេះ កិច្ចព្រមព្រៀងរវាងដៃគូសាកលវិទ្យាល័យបាត់ដំបង សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងបណ្តាស្ថាប័នឧត្តមសិក្សាដែលពាក់ព័ន្ធនៃតំបន់អុកស៊ីតានី ក៏បានចុះហត្ថលេខាសហការជាបន្តបន្ទាប់។ សាលាស្ថាបត្យកម្មជាតិជាន់ខ្ពស់ទូលូស៍ (Ecole Nationale Supérieure d'Architecture de Toulouse) និងសាកលវិទ្យាល័យទូលូស៍ហ្សង់ហ្សូរេស (Université Toulouse Jean Jaurès) បានរួមសហការបង្កើតគម្រោងមួយដោយផ្តោតជាចម្បងលើការអភិវឌ្ឍផ្នែកទេសចរណ៍វប្បធម៌ប្រកបដោយទំនួលខុសត្រូវ ដែលជាប្រភពនៃការងារនិងប្រាក់ចំណូល និងការបង្កើតសកម្មភាពទេសចរណ៍តំបន់ ដើម្បីជានាជួយសម្រាលដល់ការកកកុញទេសចរ នៅតំបន់ទេសចរណ៍អង្គរ។ អាស្រ័យហេតុនេះ បេតិកភណ្ឌវប្បធម៌ក្នុងខេត្តបាត់ដំបង រួមមានស្ថាបត្យកម្មសម័យអាណាព្យាបាលបារាំង សំណង់ផ្ទះខ្មែរបុរាណ វត្តអារាម គួរតែត្រូវលើកតម្កើង ផ្សព្វផ្សាយ និងរក្សាការពារ។

ខ្ញុំមានសេចក្តីសោមនស្សរីករាយណាស់ដោយបានឃើញថា កិច្ចព្យាយាមខិតខំប្រឹងប្រែង ទទួលបានជោគជ័យ។ សៀវភៅនេះគឺសក្ខីកម្មផង និងជាលទ្ធផលផ្លែផ្កានៃកិច្ចខិតខំសម្រេចការងាររយៈពេលជាច្រើនឆ្នាំកន្លងមកផង។ ថ្ងៃនេះ ខ្ញុំសូមរួមចំណែកចូលរួមត្រេកអរសាទរនឹងដំណើរជោគជ័យនេះ និងសូមកោតសរសើរដល់ដៃគូសហការនានាដែលបានចូលរួមចំណែកក្នុងការសម្រេចការងារនេះ ដែលនឹងក្លាយជាគន្លឹះសំខាន់បន្តទៀតក្នុងការស្នើដាក់បេក្ខភាពក្រុងបាត់ដំបងជាទីក្រុងបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូ។

12 000 km séparent l'Occitanie de Battambang. Pourtant les ressemblances entre ces deux régions sont fortes : des territoires agricoles, un patrimoine riche et varié, une activité touristique importante qu'il convient de maîtriser. Alors naturellement, des échanges, des rencontres, des études et des projets, mais aussi des amitiés se sont construits au fil des ans depuis 2015.

C'est avec conviction et énergie que la région Occitanie a fait le choix d'accompagner nombre de ces actions. Des actions très concrètes, portées par des associations, ONG, établissements d'enseignement supérieur d'Occitanie en lien avec leurs partenaires cambodgiens, dans les domaines de l'agriculture, l'éducation, la culture et le patrimoine, la santé et la justice.

À chaque fois, nous avions le souci de répondre à des besoins identifiés comme prioritaires par la province de Battambang. À chaque fois, nous avons souhaité faire appel au savoir-faire et à l'expertise des acteurs régionaux et locaux compétents en lien étroit avec les autorités nationales.



Rapidement, la question de la préservation et de la valorisation du patrimoine bâti de la province de Battambang est apparue centrale, tout comme la nécessité de renforcer la formation, notamment universitaire, pour y répondre. Des accords impliquant l'université de Battambang, des établissements d'enseignement supérieur de Phnom Penh et des établissements d'Occitanie se sont ainsi développés. L'École nationale supérieure d'architecture de Toulouse et l'université Toulouse – Jean Jaurès se sont associées pour bâtir un projet qui portait, notamment, l'ambition majeure de développer un tourisme culturel responsable, source d'emplois, et de garantir un équilibre régional face à la concentration des aides et des touristes autour d'Angkor. Il était évident en effet que le patrimoine de Battambang, son architecture coloniale, ses maisons traditionnelles en bois sur pilotis et ses temples se devaient d'être connus, protégés.

Je suis heureuse de constater que le pari est réussi. Ce livre est à la fois la preuve et la synthèse de ces années de travaux. Je ne peux que me réjouir du chemin parcouru et féliciter aujourd'hui les différents partenaires pour leur engagement dans cette démarche qui aura été une étape clef pour la candidature de Battambang au patrimoine mondial de l'UNESCO.

# S. E. M. Lou Sok
## Gouverneur du conseil des gouverneurs de la province de Battambang

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
* * * * * *

**បុព្វកថា**
**ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង**

ក្នុងនាមអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ខ្ញុំពិតជាមានសេចក្ដីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបានរួមចំណែកក្នុងការលើកតម្លៃមរតកបេតិកភណ្ឌវប្បធម៌ ជាពិសេសស្ថាបត្យកម្ម និងទីក្រុងបុរាណនៅខេត្តបាត់ដំបង។ កន្លងមកសាលាខេត្តបាត់ដំបង បានសហការជាមួយនឹងតំបន់អុកស៊ីតានីនៃសាធារណៈរដ្ឋបារាំង ដើម្បីសិក្សា និងផ្សព្វផ្សាយតម្លៃបេតិកភណ្ឌក្នុងខេត្តបាត់ដំបង។ តាមរយៈកិច្ចសហការនេះ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សាលាស្ថាបត្យកម្មជាតិជាន់ខ្ពស់ទូលូស៍ (École Nationale Supérieure d'Architecture de Toulouse) និងសាកលវិទ្យាល័យទូលូស៍ហ្សង់ហ្សូរ៉េស (Université Toulouse Jean Jaurès) រួមគ្នាបង្កើតជាកម្មសិក្សាចុះទៅសិក្សាស្រង់ទិន្នន័យ និងវិភាគផ្ទាល់អំពីទេសភាពជនបទ និងក្រុងដែលជាអត្តសញ្ញាណខេត្ត ធ្វើសម្រង់ប្លង់នៅតាមបុរាណដ្ឋាននានា រួមមានវត្តអារាម ផ្ទះបុរាណខ្មែរ និងជាពិសេសទីក្រុងចាស់ ព្រមជាមួយនឹងស្ថាបត្យកម្មសម័យអាណានិគមបារាំងដែលមានទីតាំងនៅស្របតាមដងស្ទឹងសង្កែ។ ក្រោយពីមានកិច្ចសហប្រតិបត្តិការចាប់តាំងពីឆ្នាំ២០១៦ រហូតមកដល់ឆ្នាំ២០២២ ដៃគូសហការទាំងអស់បានរៀបចំសិក្ខាសាលាអន្តរជាតិមួយកាលពីថ្ងៃទី១៩ ដល់ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២ កន្លងមកនៅសាកលវិទ្យាល័យជាតិបាត់ដំបង ក្រោមប្រធានបទ **"ការលើកតម្លៃមរតកស្ថាបត្យកម្ម និងការរៀបចំក្រុងខេត្តបាត់ដំបង"** ក្នុងគោលបំណងផ្សព្វផ្សាយ និងលើកតម្លៃបេតិកភណ្ឌវប្បធម៌ក្នុងខេត្តបាត់ដំបង ដោយបង្ហាញនូវលទ្ធផលសិក្សា ការស្រាវជ្រាវរបស់សាស្ត្រាចារ្យ អ្នកស្រាវជ្រាវនានា និស្សិតផ្នែកស្ថាបត្យកម្ម និងអ្នកបុរាណវិទ្យា។

ដោយឡែក ការបោះពុម្ពសៀវភៅអំពី **"បេតិកភណ្ឌតាមដងស្ទឹងសង្កែ"** ដែលជាលទ្ធផលនៃការសិក្សា និងសិក្ខាសាលាកន្លងមកនេះ ពិតជាមានសារៈប្រយោជន៍យ៉ាងសំខាន់សម្រាប់ខេត្តបាត់ដំបង ដើម្បីផ្សព្វផ្សាយ បង្ហាញពីតម្លៃបេតិកភណ្ឌ និងអត្តសញ្ញាណផ្ទាល់របស់ខេត្ត និងក៏ជាដើមទុនក្នុងការសិក្សាបន្តបន្ទាប់ផងដែរ ជាពិសេសគឺអាចយកមកបញ្ចូលជាមួយនឹងគម្រោងអភិវឌ្ឍន៍ខេត្តបាត់ដំបង ក៏ដូចជាក្រុងបាត់ដំបងប្រកបដោយនិរន្តរភាព។

ហេតុដូចនេះ ខ្ញុំសូមលើកទឹកចិត្ត និងអំពាវនាវដល់ស្ថាប័នរាជរដ្ឋាភិបាល អាជ្ញាធរដែនដី និងភាគីពាក់ព័ន្ធ ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់រួមគ្នាថែរក្សា ការពារ និងផ្សព្វផ្សាយសម្បត្តិបេតិកភណ្ឌវប្បធម៌រូបិយ និងអរូបិយនៃខេត្តបាត់ដំបង ដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍ ហើយអាចរក្សាទុកដល់កូនចៅជំនាន់ក្រោយជាមូលដ្ឋានក្នុងការសិក្សាស្រាវជ្រាវបន្តទៀត។

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
បាត់ដំបង ថ្ងៃទី ១២ ខែ ១០ ឆ្នាំ២០២៣
**អភិបាលខេត្ត**

**សុខ លូ**

Au nom du conseil des gouverneurs de la province de Battambang, je suis très heureux d'avoir contribué à la promotion du patrimoine culturel, notamment de l'architecture et de la ville ancienne à Battambang. Dans le passé, la préfecture de Battambang a coopéré avec la région d'Occitanie de la République française pour étudier et promouvoir la valeur du patrimoine dans la province de Battambang. À travers cette collaboration, l'université royale des beaux-arts, l'École nationale supérieure d'architecture de Toulouse et l'université Toulouse – Jean Jaurès ont conjointement réalisé des stages d'étude visant à collecter et analyser des données sur les paysages de campagne et de ville, qui représentent l'identité de la province, en dressant des plans des sites archéologiques, dont les pagodes anciennes, les maisons traditionnelles khmères, et surtout l'ancien quartier, ainsi que l'architecture coloniale française, située le long de la rivière Sangker. Après la coopération de 2016 à 2022, tous les partenaires ont coorganisé un séminaire international du 19 au 20 décembre 2022 à l'université nationale de Battambang sous le thème « Valorisation du patrimoine architectural et de l'urbanisation de la province de Battambang » afin de promouvoir et revaloriser le patrimoine culturel de la province en présentant les résultats de recherches des professeurs, chercheurs, étudiants en architecture et archéologie.



En plus, la publication de l'ouvrage *La rivière Sangker à Battambang* issu du séminaire est très importante pour la province de Battambang dans la promotion de la valeur du patrimoine et de sa propre identité. Ce livre constitue une ressource documentaire exploitable dans les études ultérieures et surtout il peut être intégré au projet de développement durable de la province ainsi que la ville de Battambang.

Par conséquent, je voudrais encourager et faire appel au gouvernement royal, aux autorités locales et aux parties prenantes, ainsi qu'à tous les citoyens, à préserver, protéger et promouvoir conjointement le patrimoine culturel matériel et immatériel de Battambang au profit du développement et pouvant être préservé comme base pour des recherches ultérieures pour les générations futures.

Battambang, le 12 octobre 2023
Gouverneur de la province
SOK Lou